ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈទាំងអស់ឲ្យបានជ្រាបថា កាលពីព្រឹកថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩កន្លងទៅ ក្រុមជនអនាមិកបាន (Hacker) បានយកទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងមុខងារសាធារណៈ ដែលមានអាសយដ្ឋាន http://www.facebook.com/CivilServiceCambodia/ យកទៅគ្រប់គ្រង បណ្តាលឲ្យការផ្សព្វផ្សាយអំពីព័ត៌មានផ្សេងៗ ទាក់ទងទៅនឹងបេសកកម្មរបស់ក្រសួងនិងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ តាមរយៈទំព័រហ្វេសប៊ុកផ្លូវការនេះត្រូវបានខកខានមួយរយៈ ។

ដោយមានកិច្ចខិតខំប្រឹងប្រែងពីក្រុមការងារបណ្តាញសង្គមហ្វេសប៊ុកក្រសួង និងក្រសួងស្ថាប័នពាក់ព័ន្ធ ទំព័រហ្វេសប៊ុកផ្លូវការនេះ ត្រូវបានក្រសួងមុខងារសាធារណៈយកមកគ្រប់គ្រង និងដាក់ឱ្យដំណើរការជាធម្មតាឡើងវិញ ចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ នៅវេលាម៉ោង២៣:១៦នាទី។

អាស្រ័យហេតុនេះ សូមសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃសុក្រ ៦កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៩*

ផ្លូវវេត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh